# KhmerPost USA

សុបិន : (267) 253-3947, សែម : (781) 244-0522

មាតិការឿង ទំព័រ

១-រមណីយដ្ឋានទេសចរណ៍......................................០២
២-សាខាគណបក្សប្រជាជនកម្ពុជា&យុទ្ធនាការឃោសនារក.....០៣
៣-រមណីយដ្ឋានទេសចរណ៍នៅខេត្តស្ទឹងត្រែង........................០៥
៤- កុំលែងគ្នាអីអូនអើយ.........................................................០៨
៥- វិធីបន្ធូរនិងលំហែកាយនិងចិត្ត.............................................១៣
៦-ប្រវត្តិរណសិរ្សជាតិរំដោះប្រជាពលរដ្ឋ.....................................១៤

VOL. 06 ISSUE 107 May.25th - Jun.07th, 2012

# សមាគមបំរើសេវាមនុស្សចាស់ ឈ្មោះ Passi ចែកប័ណ្ណកោតសរសើរអ្នកបំរើសហគមន៍អាស៊ី

**ដោយ: ខ្មែរប៉ុស្តិ៍**


អ្នកស្រី ឆយ


ឡូរ៉ែន

ទីក្រុងតូចស្អាតមួយឈ្មោះ Blue bell នៃរដ្ឋ ផេនស៊ីវេនាចំងាយប្រមាណជា ២០មាយ៍ ពីខាងលិចហ្វីឡាដែលហៀ សមាគម Passi បានរៀបពិធីជប់ លៀងដ៏ត្រចះត្រចង់មួយ ដែលហៅថា Gala ប្រចាំឆ្នាំទី៦ ដោយមានភ្ញៀវប្រមាណជាង២០០នាក់ចូលរួម នៅភោជ- នីយដ្ឋានអាស៊ីកំរិតខ្ពស់មួយ ឈ្មោះ ឡាយឡាយ កាលពី រាត្រី ទី១៧ ឧសភា ឆ្នាំ២០១២ កន្លងទៅនេះ ។.Passi ជាសមាគម មិនរកប្រាក់ចំណេញ


ឡានីកា

តទៅទំព័រទី ៧

# សហគមន៍ខ្មែរនៅតំបន់ញូអិនគ្លិន ឱ្យតម្លៃខ្ពស់ដល់“ប្រេសក្លឹប”


លោក ហុង







●●●នៅដើមរដូវក្ដៅឆ្នាំ២០១២មកដល់ ខ្មែរប៉ុស្តិ៍ ស.រ.អា បានអញ្ជើញថ្នាក់ដឹកនាំនិងសហគមន៍ខ្មែរនៅឡូវែល-លីន-រីវែ នៃរដ្ឋម៉ាសាឈូសែតនឹងតំបន់ផ្សេងទៀត ដូចជារ៉ូដអាយឡិន-កុណិច ទីកិត មកចូលរួមកម្មវិធីប្រេសក្លឹប រៀបចំជាដំបូងបង្អស់ជូនជាកិត្តិយសដល់សហគមន៍ខ្មែរញូអិនគ្លិននៅភោជនីយដ្ឋានអាស៊ី សង់តាមក្បាច់បុរាណចិន នៅរ៉ូបឹន ។ ឆ្លើយតបនឹងសេចក្ដីអញ្ជើញនេះ ភ្ញៀវប្រមាណ៨០ទៅ៩០នាក់ បានអញ្ជើញមកអបអរសាទរពិធីដែលពុំមានពីមុនមកហើយ វាយតម្លៃខ្ពស់ចំពោះគំនិតដែលរៀបចំប្រេសក្លឹប នៅថ្ងៃទី៤

តទៅទំព័រទី ០៩

# បោះឆ្នោតឃុំ-សង្កាត់នៅកម្ពុជាឆ្នាំ២០១២

**ដោយ : ខ្មែរប៉ុស្តិ៍**

ការបោះឆ្នោតឃុំ-សង្កាត់នឹងផ្ដើមជាលើកទី៣នៅ ថ្ងៃទី៣ខែមិថុនា ឆ្នាំ២០១២ ដើម្បីដណ្ដើមអាសនៈ ឃុំនិង សង្កាត់ចំនួន១៦៣៣ ដោយមានគណបក្សចំនួន១០ចូលប្រកួត ។ គឺជាការបោះឆ្នោតមូលដ្ឋានសំខាន់បំផុតសំរាប់ជំហរនៃគណបក្សនយោបាយខ្មែរ ។ គណបក្សប្រជាជន កាន់អំណាចកាន់កាប់ស្ទើរតែគ្រប់ឃុំ-សង្កាត់ទាំងអស់នៃប្រទេសកម្ពុជា បន្ទាប់មកមានគណបក្ស សម រង្ស៊ី ដែលដណ្ដើមឋានៈជាមេឃុំ-ចៅសង្កាត់ខ្លះ ជាពិសេសនៅក្បែរទីប្រជុំជននិងទីក្រុងរីឯគណបក្សសិទ្ធិមនុស្ស ទើបនឹងចូលរួមបោះឆ្នោតឃុំ-សង្កាត់ជាលើកដំបូងពុំទាន់មានមេឃុំឬ ជំទប់នៅតំបន់ណាមួយនៅឡើយទេ ។

ក្នុងចំណោមប្រជាពលរដ្ឋចេញសមត្ថភាពចំនួន១៤ លាននាក់ មាន៩លាននាក់ដែលបានចុះឈ្មោះដើម្បីបោះឆ្នោតជូនអាសនៈ ១១.៤៥៩ នៃក្រុមប្រឹក្សាឃុំ-សង្កាត់ ១៦៣៣នៅ ។

គណបក្សប្រជាជនមានបេក្ខជនឈរឈ្មោះទាំង ១៦៣៣ ឃុំ-សង្កាត់


លោក ជា ស៊ី គណបក្សប្រជាជន

គណបក្ស សម រង្ស៊ី ដាក់បេក្ខជន ១៦១៥ សង្កាត់-ឃុំ


សម រង្ស៊ី
គណបក្សសមរង្ស៊ី

គណបក្ស ហ៊្វុន សិនប៉ិច ដាក់បេក្ខជន១៤១៣ ឃុំ-សង្កាត់


ញឹក ប៊ុនឆៃ គណបក្សហ៊្វុនស៊ិនប៉ិច

គណបក្សសិទ្ធិមនុស្សដាក់បេក្ខជន១០៧០ ឃុំ-សង្កាត់


កឹម សុខា គណបក្សសិទ្ធិមនុស្ស

គណបក្សសម្ព័ន្ធប្រជាធិបតេយ្យដាក់បេក្ខជន២៣ ឃុំ-សង្កាត់

គណបក្សប្រជាធិបតេយ្យដាក់បេក្ខជន៩ ឃុំ-សង្កាត់

គណបក្សចលនាប្រជាធិបតេយ្យដាក់បេក្ខជន២ឃុំ-សង្កាត់

ទោះបីជានៅឱកាសបោះឆ្នោតឃុំ-សង្កាត់នេះមានការគំរាមកំហែងនៅលើពលរដ្ឋនឹងគណបក្សប្រឆាំងជារៀលរាល់ថ្ងៃក្ដីលទ្ធផលបានដូចតទៅ :

**ឆ្នាំ២០០២** គណបក្ស៨ចូលបោះឆ្នោតសំរាប់អាសនៈ ១១,២៦១

គណបក្សប្រជាជនបាន៧,៧០៣

គណបក្សហ៊្វុនស៊ិនប៉ិចបាន២,២១១

គណបក្ស សម រង្ស៊ី បាន១,៣៤៦

គណបក្សប្រជាធិបតេយ្យខ្មែរបាន១

**ឆ្នាំ២០០៧** គណបក្ស១២ចូលប្រកួតបាន

តទៅទំព័រទី ០៦

# រមណីយដ្ឋានទេសចរណ៍ នៅខេត្តពោធិ៍សាត់



ខេត្តពោធិ៍សាត់គ្របដណ្តប់មួយភាគធំដោយជួរភ្នំ ហើយបើយើងធ្វើដំណើរពីភ្នំពេញទៅខេត្តពោធិ៍សាត់មានចម្ងាយផ្លូវ១៨៩គីឡូម៉ែត្រតាមផ្លូវជាតិលេខ៥ ។ ទោះបីខេត្តនេះមិនមែនជាតំបន់ដែលមានប្រាសាទបុរាណច្រើនក៏ដោយ ប៉ុន្តែខេត្តនេះក៏មានរមណីយដ្ឋានទេសចរណ៍ជាច្រើន កន្លែងដើម្បីទាក់ទាញភ្ញៀវទេសចរឱ្យមកកម្សាន្តផងដែរ ដែលមានដូចខាងក្រោមនេះ :

**-កោះសំពៅមាស :** សួនកោះសំពៅមាសស្ថិតនៅកណ្តាលស្ទឹងពោធិ៍សាត់នៅមុខមន្ទីរពេទ្យពោធិ៍សាត់ចម្ងាយ១គីឡូម៉ែត្រពីស្ពានថ្មទីមួយ ។ កោះសំពៅមាស គឺជាការអភិវឌ្ឍន៍របស់ខេត្តដើម្បីទាក់ទាញភ្ញៀវទេសចរ និងអ្នករស់នៅក្នុងតំបន់ឱ្យមកកម្សាន្ត ហើយក៏មានរូបចម្លាក់វិចិត្រៗដែលបង្ហាញពីរូបភាពក្នុងវប្បធម៌ខ្មែរ ។

**-ទឹកជ្រោះច្រកល្មៀង :** ទឹកជ្រោះច្រកល្មៀងគឺជារមណីយដ្ឋានទេសភាពបែបធម្មជាតិដែលមានទឹកជ្រោះ និងព្រៃឈើ ។ ភ្ញៀវទេសចរអាចហែលទឹកលេង ឬចុះលេងក្នុងស្ទឹង ឬសម្រាកនៅក្នុងភាពស្ងៀមស្ងាត់ដែលមានស្ទឹងចម្ងាយ២គីឡូម៉ែត្រ ។ ដើម្បីទៅដល់ទីនោះត្រូវទៅដល់ឃុំឈើទុំស្រុកក្រគ និងមានចម្ងាយ៧៣គីឡូម៉ែត្រភាគអាគ្នេយ៍ក្រុងពោធិ៍សាត់ និងប្រហែលជា៤១គីឡូម៉ែត្រពីផ្សារក្រគ ។ គេត្រូវចំណាយពេលប្រហែល២ម៉ោងដោយជិះម៉ូតូ និងមួយម៉ោងកន្លះដោយបើកបររថយន្ត pick-up ពីខេត្តពោធិ៍សាត់ ។ ការជិះម៉ូតូឌុបអាចមានតម្លៃប្រហែលពី១០ទៅ១៥ដុល្លារសម្រាប់ការធ្វើដំណើរទៅ និងមក ។

**-ភ្នំឡាងគ្រោច :** ជាតំបន់ភ្នំដ៏ស្រស់ស្អាតមួយដែលស្ថិតនៅតាមបណ្តោយផ្លូវលេខ៥៥ ។ ភ្នំនេះមានចំណោទឡើងប្រហែល១០១៣០ម៉ែត្រដែលមានទេសភាពដើមឈើខ្ពស់ៗ និងថ្មធម្មជាតិធំៗ ។ តំបន់នេះស្ថិតនៅចម្ងាយ៤៩គីឡូម៉ែត្រភាគអាគ្នេយ៍ក្រុងពោធិ៍សាត់ ឬ១៧គីឡូម៉ែត្រខាងត្បូងផ្សារក្រគស្ថិតក្នុងឃុំស្វាយស ។ ស្រុកក្រគក៏ស្ថិតក្នុងទិសដៅដូចគ្នាទៅច្រកល្មៀង និងចំណាយពេលត្រឹមតែមួយម៉ោងប៉ុណ្ណោះ ហើយធ្វើដំណើរទៅតំបន់នោះគឺអាចទាំងជិះម៉ូតូ និងរថយន្ត pick-up ។ ម៉ូតូឌុបមានតម្លៃប្រហែល៨ដុល្លារសម្រាប់ការធ្វើដំណើរទៅ និងមកពីក្រុងពោធិ៍សាត់ ប៉ុន្តែត្រូវចរចាតម្លៃជាមុនសិនមុនពេលចាកចេញមក ។

**-អូរដា :** អូរដាជាកន្លែងធម្ម-ជាតិដ៏មានប្រជាប្រិយភាព និងស្រស់ស្អាតដោយមានទីតាំងតាមបណ្តោយជួរភ្នំក្រវាញចម្ងាយ៥៥គីឡូម៉ែត្រភាគខាងត្បូងក្រុងពោធិ៍សាត់ និង២៦គីឡូម៉ែត្រពីស្រុកភ្នំក្រវាញ ។ នៅតាមបណ្តោយផ្លូវមានខ្យល់បក់យ៉ាងត្រជាក់អ្នកដំណើរអាចមើលឃើញព្រៃភ្នំ និងឮសំឡេងបក្សីយំប្រចាំរដូវជាហូរហែ ។ ការធ្វើដំណើរត្រូវចំណាយពេលប្រហែលត្រឹមតែមួយម៉ោងកន្លះប៉ុណ្ណោះ ដើម្បីទៅដល់ទីនោះក្នុងរដូវប្រាំងដោយជិះម៉ូតូ និងមានតម្លៃពី១០ទៅ១៥ដុល្លារ ។ ប៉ុន្តែនៅរដូវវស្សាមិនអាចទៅដល់ឡើយ ។

**-ល្បាក់កំរោញ :** សម្រាប់ស្ទឹងដែលមានទេសភាពស្រស់ស្អាតពេញមួយឆ្នាំ គឺស្ទឹងល្បាក់កំរោញដែលជារមណីយដ្ឋានធម្មជាតិមួយស្ថិតនៅបណ្តោយផ្លូវលេខ៥៦ (ខេត្តពោធិ៍សាត់ ស្រុកវាលវែង) និងមានចម្ងាយ៥៣គីឡូម៉ែត្រភាគ និរតីក្រុងពោធិ៍សាត់ ។ រមណីយ ដ្ឋាននេះស្ថិតនៅក្នុងភូមិអង្ក្រង ឃុំសំរោង ស្រុកភ្នំក្រវាញ ។ ទឹកធ្លាក់ដ៏ស្រស់ស្អាតហូរធ្លាក់លើថ្មធំៗជាច្រើនមិនថា រដូវប្រាំង ឬរដូវវស្សាឡើយ ។ ការធ្វើដំណើរត្រូវចំណាយពេលមួយម៉ោងដោយការបើកបររថយន្ត pick-up និងមួយម៉ោងកន្លះដោយការបើកបរម៉ូតូ ។ ម៉ូតូឌុបអាចមានតម្លៃ៨ដុល្លារទាំងទៅ និងមក ។

**-វត្តស្បូវរាជ :** វត្តស្បូវរាជជាវត្តព្រះពុទ្ធសាសនាដែលត្រូវបានជួសជុលឡើងវិញឱ្យដូចភាពរុងរឿងពីអតីតកាល និងមានទីតាំងក្នុងភូមិស្បូវរាជ ឃុំលាជ ស្រុកក្រវាញ ។ វត្តនេះត្រូវបានកសាងឡើងយ៉ាងហោចណាស់ក៏ជាង៤០០ឆ្នាំកន្លងមកដែរ ។

**-វាលវែង :** មានទីតាំងនៅភាគអាគ្នេយ៍ ខេត្តពោធិ៍សាត់ និងចម្ងាយ១២៥គីឡូម៉ែត្រពី ក្រុងពោធិ៍សាត់ ។ មានផ្ទះសំណាក់នៅក្នុងស្រុកប្រមោយសម្រាប់ឱ្យភ្ញៀវស្នាក់នៅតម្លៃ៥ដុល្លារក្នុងមួយយប់ ហើយភោជនីយដ្ឋានមួយចំនួនមានបម្រើម្ហូបក្នុងស្រុកផងដែរ ៕


天 THIÊN TÂN 新 食坊
Vietnamese & Chinese Restaurant
ភោជនីយដ្ឋាន ធានតឹង



យើងមានម្ហូបវៀតណាមល្បីគ្រប់មុខ ដូចជា ហ្វើ គុយទាវ នំបញ្ចុក បាយ បាញយើងខ្ញុំមានម្ហូប
សម្រាប់ទទួលគ្រួសារ សម្លម្ជូរយួន ត្រីខផ្អាំងជី និងម្ហូបឆា ពិសេសមានត្រីរស់មង្កងស្រស់
ក្តាមកាណេកដា អន្ទង់រស់ មានម្ហូបសាច់គោបីមុខ ញាំស្វាយ ស្ងោរគ្រឿងពពៃ ហ្វើមានស្រស់ និងហ្វើសាច់គោ
ទទួលពិធីជប់លៀងគ្រួសារ ជប់លៀងខួបកំណើតរៀបការ អង្គប្រជុំផ្សេងៗ



បង្កងពិសេស
$14.95





FAMILY DINER SPECIAL $88 ម្ហូបពិសេសសំរាប់គ្រួសារ

Fish Maw Soup............ស៊ុបក្រពះត្រី
Fresh Steaming Fish............ត្រីស្រស់ចំហុយ
Lobster with Scalloin and Ginger............ឆាឡបស្ទ័រជាមួយខ្ទឹមក្រហមនឹងខ្ញី
Clam sauté with black bean sauce............ឆាគ្រំ និងទឹកសណ្តែកសៀង
Snow pea tips with garlic............ត្រួយសណ្តែកស្នូភីឆាជាមួយខ្ទឹមស
Dessert............បង្អែម
Family of 4-6............សម្រាប់គ្រួសារ៤-៦នាក់
Please call for Reservation............សូមអញ្ជើញទូរស័ព្ទដើម្បីរក្សាតុ

701 Adams Avenue
Philadelphia, PA 19124
215-904.6543
បើកទ្វារ៧ថ្ងៃ 10am-10pm

BYOB Welcome
យកស្រាចូលពិសារបាន



Birthday/ Function Party available (15 Tables)

# សាខាគណបក្សប្រជាជនកម្ពុជានៅហ្វីឡា ស្រង់ឈ្មោះបក្សប្រឆាំងបញ្ជូនទៅស្រុកខ្មែរ

**ដោយ : អ៊ឹម លឿម**

សាខាគណបក្សប្រជាជនកម្ពុជានៅហ្វីឡា ស្រង់ឈ្មោះបក្សប្រឆាំងបញ្ជូនទៅស្រុកខ្មែរ យោងតាមប្រភពព័ត៌មានគួរឱ្យជឿទុកចិត្តមួយធ្លាយចេញពីអ្នកគាំទ្រគណបក្សប្រជាជនកម្ពុជាប្រចាំរដ្ឋផែនស៊ុលវៃនៀ(PA) បានឱ្យដឹងថា ថ្នាក់ដឹកនាំរបស់សាខាគណបក្សប្រជាជនកម្ពុជាប្រចាំរដ្ឋផែនស៊ុលវៃនៀបានស្រាវជ្រាវ និងស្រង់ឈ្មោះរបស់សកម្មជនគណបក្សប្រឆាំងនៅក្នុងទីក្រុងហ្វីឡាដែលហ្វៀ ដើម្បីបញ្ជូនឈ្មោះអ្នកប្រឆាំងទាំងនោះទៅកាន់ស្នាក់ការកណ្តាលរបស់បក្សប្រជាជនកម្ពុជានៅឯភ្នំពេញ ។

ទោះជាព័ត៌មានពុំបានលំអិតឱ្យបានច្បាស់ និងឱ្យចំឈ្មោះគណបក្សប្រឆាំងណាមួយក្តីតែអ្នកវិភាគអាចយល់ថា ទំនងជាសំដៅទៅលើគណបក្សសិទ្ធិមនុស្ស និងគណបក្ស សម រង្ស៊ី នៅហ្វីឡាដែលហ្វៀ ។

ទាក់ទងនឹងព្យុះព័ត៌មានដ៏រសើបនេះ"ខ្មែរផូស"បានធ្វើការទំនាក់ទំនងសុំការបំភ្លឺពីលោក សុខ យុទ្ធ ប្រធានសាខាគណបក្សប្រជាជនកម្ពុជាប្រចាំរដ្ឋផែនស៊ីវៃនៀ កាលពីថ្ងៃអង្គារទី៨ ខែឧសភាកន្លងមកនេះ ដោយលោកថ្លែងយ៉ាងខ្លីថា"ពុំបានជ្រាបអំពីព័ត៌មាននេះឡើយ..."។

ដោយឡែកលោក គីម សុភ័ក្រ ជាសកម្មជនរបស់សាខាគណបក្សប្រជាជនកម្ពុជា និងជាអនុប្រធានកុងស៊ុលកិត្តិយសប្រចាំទីក្រុងហ្វីឡាដែលហ្វៀបានបំភ្លឺប្រាប់ខ្មែរ"ផូស"នៅថ្ងៃជាមួយគ្នានោះថា "តាមពិតគេពិតជាបានធ្វើមែន ប៉ុន្តែគេពុំបានយកឈ្មោះអ្នកទាំងនោះធ្វើអ្វីទេ ដោយគេគ្រាន់តែចង់ដឹងថា តើនៅហ្វីឡាដែលហ្វៀយើងនេះមានបងប្អូនខ្មែរប៉ុន្មាននាក់ដែលគាំទ្រគណបក្សណានោះ...."។ ឆ្លើយតបចំពោះសំណួររបស់"ខ្មែរផូស"ដែលសួរថា តើអ្នកប្រឆាំងទាំងនោះអាចមានមានបញ្ហាដែរឬទេ នៅពេលទៅលេងស្រុកកំណើតនោះ?។ លោក សុភ័ក្រ បំភ្លឺថា "រឿងទៅស្រុកខ្មែរជារឿងបុគ្គលពុំពាក់ព័ន្ធជាមួយបក្សប្រឆាំងឡើយ ដូច្នេះពុំចាំបាច់ខ្វល់ឡើយ...។

លោក មាស ជាប្រធានសាខាគណបក្ស សម រង្ស៊ី ប្រចាំរដ្ឋផែនស៊ីវៃនៀ កាលពីថ្ងៃទី៨ ខែឧសភាកន្លងមកនេះបានសំដែងនូវប្រតិកម្មយ៉ាងខ្លាំងចំពោះដំណឹងស្តីពីការស្រង់ឈ្មោះសកម្មជនគាំទ្រគណបក្សប្រឆាំងនេះ លោក មាស ថ្លែងថា "លោកក៏បានជ្រាបនូវព័ត៌មាននេះជាង២ខែមកហើយ តែលោកនៅពុំទាន់មានភស្តុតាងច្បាស់លាស់ណាមួយនៅឡើយទេ ហើយលោកកំពុងតែស្រាវជ្រាវដែរថា តើនរណាជាអ្នកធ្វើបែបហ្នឹង?។ លោកជាបន្តថា: តាមពិតគណបក្សប្រជាជននៅស្រុកខ្មែរប្រហែលគេពុំប្រើឱ្យធ្វើបែបហ្នឹងទេ ប៉ុន្តែសម្រាប់បុគ្គលឡេមឡឺមបែរជាធ្វើ ដើម្បីផ្គាប់ចិត្តមេ និងដើម្បីយកមុខមាត់តែប៉ុណ្ណោះ ហើយទង្វើបែបហ្នឹងជាការខុសទៅនឹងរដ្ឋធម្មនុញ្ញរបស់សហរដ្ឋអាមេរិកយ៉ាងធ្ងន់ធ្ងរ ។

លោកបន្តថា បើមានភស្តុតាងគ្រប់គ្រាន់ លោកនឹងសុំយោបល់ផ្នែកខាងផ្លូវច្បាប់នៅសាលាក្រុង។

ដោយឡែកលោក សេង សារ៉ន ប្រធានសាខាគណបក្សសិទ្ធិមនុស្សប្រចាំឆ្នេរខាងកើតនៃសហរដ្ឋអាមេរិក ក៏សំដែងនូវប្រតិកម្មយ៉ាងខ្លាំងចំពោះដំណឹងខាងលើនេះ ។ លោក សារ៉ន ថ្លែងមិនខុសពីលោក មាស ជា ថា : នេះជាទង្វើមួយដែលប្រាសចាកទាំងស្រុងទៅនឹងរដ្ឋធម្មនុញ្ញរបស់សហរដ្ឋអាមេរិក ។ លោកបន្តថា : តើចាំបាច់អ្វីត្រូវស្រង់ឈ្មោះគេដោយគ្មានការអនុញ្ញាតិពីសាមីខ្លួន។ តើយកឈ្មោះគេទៅធ្វើអ្វី ? ហើយយើងនឹងស្រាវជ្រាវនូវករណីនេះ ដើម្បីស្វែងរកការពិត ហើយយើងនឹងសហការណ៍ជាមួយ F.B.I ដើម្បីធ្វើកិច្ចការនេះ...."។

សកម្មជនគាំទ្រគណបក្សប្រជាជនកម្ពុជាម្នាក់ដែលសុំមិនបង្ហាញអត្តសញ្ញាណក៏បានបង្ហើបឱ្យ"ខ្មែរផូស"ដឹងដែរថា នោះជារឿងពិតព្រោះលោកក៏បានឃើញបញ្ជីឈ្មោះអ្នកទាំងនោះដែរ ដោយមានសកម្មជនរបស់សាខាបក្សសិទ្ធិមនុស្សនៅហ្វីឡាដែលហ្វៀ និងសកម្មជនរបស់សាខាបក្ស សម រង្ស៊ី ប៉ុន្តែត្រង់ថា មានប៉ុន្មាននាក់នោះ លោកពុំបានចាំទេ ព្រោះលោកពុំបានចាប់អារម្មណ៍ ហើយគេយកឈ្មោះទៅណាៗនោះ ក៏លោកពុំបានដឹងដែរ...។

ទោះជាយ៉ាងណាក្តីគេនៅបង្កប់ការងឿងឆ្ងល់ថា ហេតុអ្វីបានជាសាខាគណបក្សប្រជាជនកម្ពុជាប្រចាំរដ្ឋផែនស៊ីវៃនៀ(PA) ចាំបាច់ត្រូវស្រង់ឈ្មោះសមាជិកបក្សប្រឆាំងដោយគ្មានការអនុញ្ញាតិជាមុនបែបនេះ? ។ ចុះហេតុអ្វីបានជាលោក សុខ យុទ្ធ ដែលជាប្រធានសាខាបក្សប្រជាជនប្រចាំហ្វីឡាដែលហ្វៀឆ្លើយប្រាប់"ខ្មែរផូស"ថា អត់បានដឹងទេវិញ។ ប៉ុន្តែក្នុងនាមជាអនុប្រធានកុងស៊ុលកិត្តិយស់ប្រចាំក្រុងហ្វីឡាដែលហ្វៀ គឺលោក គីម សុភ័ក្រ បែរជាបានទទួលស្គាល់ថានោះជារឿងពិតទេវិញ៕

KHMER POST USA, LLC
East Coast Publication

**Pin Samkhon,**
*Publisher & Editor-in-Chief*
Email: pinsamkhon@gmail.com
*Staff Writers:* **Loeum Im**

*Contributed Writers:*
**Mam Yin, Kim Phien**
*Advertising Department*

**Soben Pin**
KhmerPostUSA@gmail.com
**267-253-3947**

**Sam Khoeun**
*Sales Consultant*
**(781) 244-0522**

*Design Staffs:*
**Leang Heng & Mong Meng**

~~~~~

KhmerPost USA, LLC is an independent newpaper that aims to facilitate mass communication among the Cambodian communities, their neighboring communities, and families. We aim to address local, community, and national news; and give an insight into Cambodia & global news. We also strive to bridge the language and cultural gaps and reduce social isolation by publishing in Khmer & English.
It published twice a month in Pennsylvanian & Massachusett.

~~~~

Semimonthly edition subscription is available within the U.S. & Canada at $60.00 and 70 Euros in Europe per year.
Money order or check is accepted and made payable to:
KhmerPost USA, LLC
438 LINDLEY AVE.
Philadelphia, PA 19120

~~~

The Khmer Post has full authorization from Bernard Krisher, the publisher of the Cambodia Daily to reproduce all the articles that are produced by the Cambodia Daily free of charge effective date: 6/19/2009

# យុទ្ធនាការឃោសនារកសំឡេងឆ្នោតឃុំ_សង្កាត់អណត្តិទី៣នៅកម្ពុជា

**ដោយ : សេងឡុង**

យុទ្ធនាការឃោសនារកសំឡេងឆ្នោត ឃុំ-សង្កាត់អណត្តិទី៣នៅកម្ពុជារបស់គណបក្សនានាទាំង១០ដែលបានឈរឈ្មោះបោះឆ្នោតថ្នាក់ឃុំ-សង្កាត់កំពុងតែធ្វើការប្រកួតប្រជែងគ្នាយ៉ាងត្រឹមត្រូវបើគិតត្រឹម ថ្ងៃ១៨-២៤ខែឧសភា ឆ្នាំ២០១២នេះ គឺសម្រាប់តែនៅរាជធានីភ្នំពេញ ។ ប៉ុន្តែនៅក្នុងគណបក្សទាំង១០នោះគឺលើកយកតែគណបក្សធំៗ៣យកមកនិយាយ គឺគណបក្សប្រជាជនកម្ពុជា .គណបក្សសមរង្ស៊ី និងគណបក្សសិទ្ធិមនុស្ស ។






ទី១គណបក្សប្រជាជនកម្ពុជា បើយើងគិតចាប់តាំងពីថ្ងៃទី១៨ទៅថ្ងៃទី២៤ខែឧសភា ឆ្នាំ២០១២ ឃើញថា បានធ្វើសកម្មភាពយ៉ាងគគ្រឹកគគ្រេង បំផុតដែលបង្ហាញពីសមត្ថភាពខ្លាំងក្លារបស់ខ្លួន ចាប់ផ្តើមពីថ្ងៃទី១គឺមានសមាជិកចូលរួមជាង១ ម៉ឺននាក់ លើកទី២មានសមាជិកចូលរួមជាង៥ ពាន់នាក់ និងលើកទី៣មានសមាជិកចូលរួមគាំទ្រចំនួនតែ៥ពាន់នាក់ ដែលមានអ្នកគាំទ្រយ៉ាង

**តទៅទំព័រទី ០៥**
~~~





# រមណីយដ្ឋានទេសចរណ៍នៅខេត្តស្ទឹងត្រែង





ខេត្តស្ទឹងត្រែង គឺជាខេត្តមួយនៅចុងខាងជើងនៃប្រទេសកម្ពុជា ។ ឈ្មោះដើមហៅថា សៀង តេង ។ ទីក្រុងរបស់ខេត្តស្ទឹងត្រែងមានឈ្មោះថា ទីក្រុងស្ទឹងត្រែង ។ ខេត្តស្ទឹងត្រែងមាន៥ស្រុកក្នុងនោះរួមមាន៣៤ឃុំ ។

ស្ទឹងត្រែងជាខេត្តដ៏ស្រស់ស្អាតមួយដែលមានទីតាំងស្ថិតនៅតំបន់ខ្ពង់រាបតាមបណ្តោយទន្លេមេគង្គដែលប្រសព្វជាមួយទន្លេសេកុង ។ ខេត្តនេះមានចម្ងាយផ្លូវប្រហែល៤៥៥គីឡូម៉ែត្រពីទីក្រុងភ្នំពេញ និង៤០គីឡូម៉ែត្រពីព្រំដែនឡាវ ។ ទីក្រុងដ៏ស្អាតនេះជាប់នឹងទីក្រុងបានលុង (ខេត្តរតនគីរី) ហើយមានស្ពានសេកុងដែលជាការទាក់ទាញ និងបម្រើសេវាដឹងជញ្ជូនយ៉ាងងាយស្រួលទៅកាន់ព្រំដែនឡាវ ។

ខេត្តស្ទឹងត្រែងមានការទាក់ទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិគួរឱ្យកត់សម្គាល់ផងដែរ ដោយមានទីកជ្រោះសុភមិត្រ និងមានទន្លេមេគង្គដ៏មានឥទ្ធិពលដែលជាជម្រកនៃផ្សោតទឹកសាបដ៏កម្រ ។ ខេត្តស្ទឹងត្រែងមានរមណីយដ្ឋានជាច្រើនកន្លែងដែលអាចទាក់ទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិឱ្យមកកម្សាន្តផងដែរ ដែលមានដូចខាងក្រោមនេះ :

**១-រមណីយដ្ឋានអូរពងមាន់ :** មានទីតាំងស្ថិតនៅភូមិពងមាន់ ឃុំអូរពងមាន់ស្រុកស្ទឹងត្រែងមានចម្ងាយផ្លូវ៩គីឡូម៉ែត្រពីទីរួមខេត្ត ។ តំបន់នេះជាប្រភេទរមណីយដ្ឋានធម្មជាតិ និងកែច្នៃ ។

**២-រមណីយដ្ឋានថាឡាបរិវ៉ាត់ :** មានទីតាំងស្ថិតនៅក្នុងស្រុកថាឡាបរិវ៉ាត់ដែលមានចម្ងាយផ្លូវ៤គីឡូម៉ែត្រពីទីរួមខេត្ត ។ តំបន់នេះត្រូវធ្វើដំណើរឆ្លងកាត់ទន្លេសេកុង និងទន្លេមេគង្គទៅកាន់ផ្លូវខេត្តព្រះវិហារ ។ ថាឡាបរិវ៉ាត់ជាប្រភេទរមណីយដ្ឋានប្រវត្តិសាស្ត្រដែលនៅក្នុងតំបន់នោះមានប្រាសាទព្រះគោកសាងឡើងនៅសតវត្សរ៍ទី៧-៨ធ្វើអំពីឥដ្ឋក្រហមក្នុងរជ្ជកាលស្តេចជ័យវរ្ម័នទី១ ។

**៣-រមណីយដ្ឋានកោះខ្សាច់ :** មានទីតាំងនៅលើដងទន្លេសេកុងដែលមានចម្ងាយផ្លូវ៥គីឡូម៉ែត្រពីទីរួមខេត្ត ។ តំបន់នេះជាប្រភេទរមណីយដ្ឋានធម្មជាតិតាមរដូវ គឺអាចទៅលេងកម្សាន្តបាននូវរដូវប្រាំង ជាពិសេសពេលបុណ្យចូលឆ្នាំប្រពៃណីខ្មែរយើង ។





**៤-វត្តហាំងខូបា :** មានទីតាំងស្ថិតនៅតាមភូមិហាំងខូបាឃុំហាំងខូស្រុកស្ទឹងត្រែងមានចម្ងាយផ្លូវ៦គីឡូម៉ែត្រពីទីរួមខេត្ត ។

ខេត្តស្ទឹងត្រែងក៏មានភាពល្បីល្បាញខាងអំពិលផ្អែម និងត្រីប៉ាស៊ីអ៊ីមានរសជាតិឆ្ងាញ់បំផុតដែលអ្នកទេសចរជាច្រើនចូលចិត្ត ៕

## បោះឆ្នោតប្រធានាធិបតី ស.រ.អា ឆ្នាំ២០១២

មិត រ៉មនី ជាបេក្ខជនប្រធានាធិបតីគណបក្សសាធារណរដ្ឋ ឥឡូវគ្មានគូរប្រជែងទៀតទេ ហើយនៅចាំងតែមួយសប្តាហ៍ទៀតនឹងទទួលកាន់តែងតាំងពីមហាសន្និបាតជាបេក្ខជនពេញសិទ្ធិរបស់គណបក្សសាធារណរដ្ឋ ដើម្បីទៅប្រកួតនឹង បារ៉ាក់ អូបាម៉ា ដែលនឹងឈរឈ្មោះជាបេក្ខជនប្រធានាធិបតីសម្រាប់គណបក្សប្រជាធិបតេយ្យអាណត្តិទី២ ។





តមកពីទំព័រទី ៣

## យុទ្ធនាការឃោសនារកសំឡេងឆ្នោតឃុំ_សង្កាត់អណត្តិទី៣...

លើសលប់បើយើងប្រៀបធៀបទៅនឹងគណបក្សផ្សេងៗ ។ ចំពោះមធ្យោបាយធ្វើដំណើរក្នុងការរៀបចំក្បួនដង្ហែយុទ្ធនាការឃោសនានៅតាមតំបន់នានានោះ គឺគណបក្សប្រជាជនគឺហាក់បីដូចជាមានភាពគគ្រឹកគគ្រេងដ៏ឱឡារឹក ដែលមានរថយន្ត និងម៉ូតូរាប់រយគ្រឿងឯណោះ ដែលសុទ្ធតែជាកម្មសិទ្ធិរបស់សមាជិកសមាជិការគណបក្សទាំងអស់។

បើតាមការបង្ហើបឱ្យដឹងពីមន្ត្រីសង្កាត់ម្នាក់ដែលសុំមិនបញ្ចេញឈ្មោះបានឱ្យដឹងក្រៅផ្លូវការថា គណបក្សប្រជាជនគឺមានលទ្ធភាពគ្រប់គ្រាន់ក្នុងការបើកយុទ្ធនាការឃោសនា ពីព្រោះសមាជិកសមាជិការនីមួយៗរបស់គណបក្សសុទ្ធមានលទ្ធភាពគ្រប់គ្រាន់ទាំងអស់ ទាំងលុយកាក់ ទាំងសម្ភារៈ ដូច្នេះហើយទើប គណបក្សប្រជាជនរៀបចំក្បួនដង្ហែបានយ៉ាងរលូន ។

**ទី២-ពីគណបក្ស សម រង្ស៊ី** សមាជិកសមាជិការចូលរួមគាំទ្រក៏មានចំនួនច្រើនគួរកត់សម្គាល់ផងដែរ ប៉ុន្តែការរៀបចំក្បួនដង្ហែហាក់បីដូចជាពុំសូវគគ្រឹកគគ្រេងដូចគណបក្សប្រជាជននោះទេ ហើយក៏មិនអចិន្ត្រៃយ៍ដែរ ។ ប៉ុន្តែបើយោងតាមតំណាងគណបក្ស សម រង្ស៊ី មួយរូបដែលសុំមិនបញ្ចេញឈ្មោះបានបង្ហើបឱ្យដឹងថា សមាជិកសមាជិការរបស់គណបក្ស សម រង្ស៊ី បានចូលរួមក្នុងមួយថ្ងៃមានប្រមាណជា៧០-៨៥ភាគរយឯណោះ បើយើងប្រៀបធៀបទៅនឹងអត្រាប្រជាពលរដ្ឋនៅរាជធានីភ្នំពេញដែលមានប្រមាណជាជាង២លាននាក់ ប៉ុន្តែមធ្យោបាយក្នុងការធ្វើជាក្បួនដង្ហែ គឺភាគច្រើនរថយន្តទាំងអស់ភាគច្រើនជួលគេយកមក ហើយក្នុងមួយថ្ងៃៗត្រូវចំណាយអស់ថវិកាច្រើនណាស់ ក្នុងរថយន្តមួយគ្រឿងចំនួនថ្ងៃតម្លៃ ៦០ដុល្លារ តែម៉ូតូកង់បីមិនទាំងស្រុងនោះទេ ពីព្រោះសមាជិកសមាជិការមួយចំនួនអាចមានលទ្ធភាព ។ ហើយចំពោះយុទ្ធនាការឃោសនាបោះឆ្នោតនេះ គឺបែងចែកទៅតាមតំបន់នីមួយៗអ្នកណាកាន់តំបន់។ ទោះបីជាលោក សម រង្ស៊ី មិននៅក្នុងប្រទេសក៏ដោយ ប៉ុន្តែដំណើរនៃយុទ្ធនាការគឺហាក់បីដូចជារលូនពុំមានភាពរាំងស្ទះនោះទេ។

ទី៣-គណបក្ស សិទ្ធិ មនុស្ស ការរៀបចំក្បួនយុទ្ធនាការការឃោសនា បើគិតត្រឹមថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១២នេះ គឺមានសមាជិកសមាជិការចូលរួមគាំទ្រមានប្រហែល៧៥០នាក់ មកពីបណ្តាខណ្ឌនានាទូរទាំងរាជធានីភ្នំពេញ ហើយបានជួលរថយន្តក្នុងមួយថ្ងៃប្រហែល ២៣ គ្រឿង ក្នុងមួយថ្ងៃៗ បានបែងចែកទៅតាមបណ្តាខណ្ឌទាំង៩ ក្នុងរាជធានីភ្នំពេញ ។ ដើម្បីបង្ហាញនូវគោលនយោបាយរបស់ខ្លួនដើម្បីឱ្យប្រជាពលរដ្ឋបានយល់ច្បាស់មុននឹងធ្វើការជ្រើសរើសអ្នកដឹកនាំ តែទោះបីជាយ៉ាងណាគណបក្សសិទ្ធិមនុស្សក៏ស្ថិតក្នុងចំណោមគណបក្សដែលមានសំឡេងគាំទ្រច្រើនគួរកត់សម្គាល់ផងដែរ៕


## ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វៀ ការិយាល័យផ្នែកអប់រំកុមារមុនថ្នាក់មត្តេយ្យ

oad Street,Philadelphia,PA 19130-215.400.4270

**ការចុះឈ្មោះចូលរៀនមុនថ្នាក់មត្តេយ្យ**

សូមកុំបង្អង់-ឆាប់ចុះឈ្មោះកូនរបស់លោក អ្នកសម្រាប់ ខែកញ្ញាឆ្នាំ២០១២ !

**ទាក់ទងមណ្ឌលមុនថ្នាក់មត្តេយ្យនៅក្នុងតំបន់ របស់លោកអ្នក**

(ស្ថិតនៅពេញទីក្រុង)

**ការរំលឹក :**

-ក្មេងត្រូវមានអាយុ៣ឆ្នាំ នៅថ្ងៃ ឬមុនថ្ងៃទី ១ ខែកញ្ញា ឆ្នាំ២០១២ ហើយមិនទាន់គ្រប់អាយុ ចូលរៀននៅថ្នាក់មត្តេយ្យនៅឡើយ
-ក្រុមគ្រួសារត្រូវតែមានប្រាក់ចំណូលតាម កម្រិតកំណត់របស់រដ្ឋសហព័ន្ធ សម្រាប់កម្មវិធី មុនថ្នាក់មត្តេយ្យ
-ក្មេង និងមាតាបិតា អាណាព្យាបាលត្រូវតែ រស់នៅក្នុងទីក្រុងហ្វីឡាដែលហ្វៀ នៃរដ្ឋជិនស៊ីល វេញ៉ា

**ដើម្បីទទួលលិខិតស្នើសុំចូលរៀន :**

-សូមទៅកាន់មណ្ឌលមុនថ្នាក់មត្តេយ្យរបស់ ក្រសួងអប់រំ
-បើសិនជាលោកអ្នកមិនអាចទៅកាន់មណ្ឌល មុនថ្នាក់មត្តេយ្យរបស់ក្រសួងអប់រំបានទេ សូមៈ
-ទូរស័ព្ទទៅលេខ215-400-4270 (ដំបូង ជ្រើសយកលេខ១ បន្ទាប់មកជ្រើសយកលេខ២) ឬ
-ចម្លងលិខិតស្នើសុំចូលរៀនពី **www.philasd.org/offices/earlychild**

**ការបម្រើទាំងអស់រួមមានៈ**

-ការអប់រំប្រដៅក្នុងបរិយាកាសសម្រាប់ក្មេង មុនថ្នាក់មតេយ្យ
-គ្រូដែលមានសញ្ញាប័ត្រ និងបុគ្គលិកដែល មានបទពិសោធន៍
-កម្មវិធីសិក្សាតាមខ្នាតសម្រាប់កុមារមុន ថ្នាក់មតេយ្យ
-អាហារ ពេលព្រឹក ពេលថ្ងៃ និងចំណីពេល ថ្ងៃរសៀល
-ការបម្រើសម្រាប់កុមារពិការ
-ព័ត៌មាន ជំនួយ ក្នុងសហគមន៍
ឱកាសសិក្សាសម្រាប់ មាតាបិតា និងក្រុម គ្រួសារ
-ការពិនិត្យ ភ្នែក និងត្រចៀក



សូមកត់សម្គាល់ : ការបំពេញ និងការដាក់ ពាក្យសុំចូលរៀននេះ មិនអាចសន្យាថា គេនឹង ទទួលក្មេងឱ្យចូលរៀនទេ។


ព័ត៌មានខ្លីៗ

## មាស សែម ជាបេក្ខជនសារជាថ្មី



មាស សែម

**ម៉ាសាឈូសែត :** បេក្ខជន មាស សែម ដែលធ្លាប់បានចេញមុខម្តងហើយក្នុងឱកាសបោះឆ្នោតកាលពី២ឆ្នាំមុន តែពុំបានសម្រេច នៅថ្ងៃទី២១ ខែឧសភា យើងបានទទួលឯកសារថ្មីមួយទៀតដែលប្រកាសថា "លោកបានដាក់ពាក្យសម្រាប់ជាបេក្ខជនព្រឹទ្ធសភារដ្ឋ ដោយមានភ្ជាប់ជាមួយនូវហត្ថលេខាគាំទ្រចំនួន៥៨០រួចហើយ ពេលនេះលោកជាបេក្ខជនស្របច្បាប់ជាផ្លូវការ ហើយ "។

**" Candidate for State Senete in 1st Essex District"**

## ទីស្នាក់ការអត្ត_កុងស៊ុលខ្មែរប្តូរទីតាំង

**ហ្វីឡាដែលហ្វៀ :**
ទីស្នាក់ការអគ្គកុងស៊ុលខ្មែរនៅហ្វីឡាដែលហ្វៀបានប្តូរទីតាំងទៅអស័យដ្ឋានថ្មីនៅ :
1834 South 7 th. Street
Philadelphia. PA 19148
ទូរស័ព្ទលេខ : ២៦៧-៥៩២-៧៣៤៤
និង២៦៧-៥៨៨ ៤៥០៣
នៅទីនោះលោកអ្នកអាចធ្វើលិខិតឆ្លងដែនខ្មែរ ធ្វើទិដ្ឋាការសម្រាប់ចូលប្រទេសកម្ពុជាបាន ។

តមកទំព័រទី ១

# បោះឆ្នោតឃុំ_សង្កាត់នៅកម្ពុជា...



យុទ្ធនាការឃោសនាគណបក្សប្រជាជន



យុទ្ធនាការឃោសនាគណបក្ស សម រង្ស៊ី




យុទ្ធនាការឃោសនាគណបក្សសិទ្ធិមនុស្ស

លទ្ធផលសំរាប់ក្រុមប្រឹក្សា១១.៣៥៣

គណបក្សប្រជាជនបាន៧៩៩៣

គណបក្ស សម រង្ស៊ី បាន ២៦៦០

គណបក្សរណប្ញទ្ធិ ៤២៥

គណបក្ស ហ៊្វុនស៊ិនប៉ិចបាន២៧៤

គណបក្សហង្សតារាចលនាប្រជាធិបតេយ្យ ១

គណបក្សពីរដែលគេចាត់ទុកថា ជាគណបក្សប្រឆាំង នឹងរដ្ឋាភិបាល គឺគណបក្ស សម រង្ស៊ី នឹងគណបក្សសិទ្ធិមនុស្ស រីឯគណបក្ស ហ៊្វុនស៊ិនប៉ិចនឹងគណបក្សនរោត្តមរណប្ញទ្ធិជាគណបក្សសម្ព័ន្ធភាពជាមួយរដ្ឋាភិបាលគណបក្សប្រជាជន ។ ចំណែកឯគណបក្សតូចៗឯទៀតត្រូវគេទទួលស្គាល់ថា រណប និងរដ្ឋាភិបាល ។

ឆ្នាំ២០១៣នឹងមានការបោះឆ្នោតសំខាន់មួយទៀតនាខែកក្កដា សម្រាប់ជ្រើសរើសសមាជិកសភាថ្មី អ្នកសង្កេតការណ៍ជាទូទៅយល់ថា លទ្ធផលនៃការបោះឆ្នោតឃុំ-សង្កាត់នឹងមានឥទ្ធិពលច្រើនលើលទ្ធផលនៃការបោះឆ្នោតសភាជាតិ ។ អវត្តមានប្រធានគណបក្ស សម រង្ស៊ី នៅឱកាសយុទ្ធនាការឃោសនាបោះឆ្នោតបានត្រូវលោក សម រង្ស៊ី ខ្លួនឯងវាយតម្លៃថា "ពុំមានជះឥទ្ធិពលណាមួយទៅលើទឹកចិត្ត ប្រជាពលរដ្ឋចំពោះគណបក្សលោកនោះទេ" តែអវត្តមាននៃបុគ្គលគណបក្សប្រឆាំងសំខាន់ជាងគេម្នាក់នេះ បានឱ្យសញ្ញាថា ការបោះ ឆ្នោតគ្មានភាពស្មើគ្នារវាងគណបក្សប្រឆាំងនឹងគណបក្សកាន់អំណាចនោះទេ ៕


# GATEWAY FAMILY DENTAL

NOW OPENED AT GATEWAY CENTER II (978) 455-5044

151 WARREN STREET, SUITE 120 LOWELL, MA 01852 (Same building as Social Security/near the courthouse)



**DR. SERENA B. CHUOP**

Dr. Serena B. Chuop was born in Cambodia. She received her Bachelor of Science from Boston University and went on to graduate from Boston University Goldman School of Dental Medicine in the year 2000. For over 10 years, she has been in private practices providing all aspects of General Dentistry. Dr. Chuop has opened a brand new state of the art dental practice that includes digital x-ray, paperless patient chart system, and brand new dental equipments.




**WE PROVIDE ALL SERVICES INCLUDING: យើងផ្តល់នូវសេវាដូចខាងក្រោមនេះ**

- CLEANING
- FILLINGS
- BONDINGS
- COSMETIC DENTISTRY
- CROWNS/BRIDGES
- DENTURES
- IMPLANTS
- EXTRACTIONS
- TEETH WHITENING
- VENEERS
- EMERGENCY DENTAL TREATMENT
- ROOT CANAL TREATMENT
- DENTAL SERVICES TO CHILDREN

- សំអាតធ្មេញ
- បំពេញធ្មេញប្រហោង
- ថ្នាំសំរាប់ការពារធ្មេញ
- ធ្មេញពាក់ជំនួសធ្មេញដែលបាក់
- ក្រាសធ្មេញពាក់
- ដាំធ្មេញតាមរន្ធធ្មេញចាស់
- ដកធ្មេញ
- ធ្វើធ្មេញឱ្យសស្អាត
- វីវនីស្រោបធ្មេញ
- ព្យាបាល និងការពារធ្មេញជាទៀងទាត់
- ព្យាបាល ឫសថ្គាមធ្មេញ
- សេវាព្យាបាលសំរាប់កុមារ

MOST DENTAL INSURANCES ACCEPTED INCLUDING MASSHEALTH FOR KIDS

FINANCING AVALIABLE

យើងទទួលនូវគ្រប់ អ៊ិន ស្វ៊ិន Masshealth for Kids

យើងសំរួលការបង់ថ្លៃព្យាបាលប្រចាំខែ

CALL FOR YOUR FREE CONSULTATION (978) 455-5044

www.gatewayfamilydental.com

តមកទំព័រទី ១

# សមាគមសេវាថែមទាំមនុស្សចាស់...

បំរើសេវាមនុស្សចាស់ជាជនជាតិអាស៊ី ។ សមាគមនេះបានចាប់ កំណើតនៅឆ្នាំ២០០៤ ដោយ អ្នកស្រី អ៊ិម ជាឆយ នៅពេលដែលអ្នកស្រីតម្រូវឈប់ធ្វើការដើម្បីបំរើសុខភាពម្តាយ ដែលមានជំងឺមហារីក ទើបអ្នកស្រីយល់ថា ទម្ងន់នៃអ្នកជំងឺវ័យជរាត្រូវថែ ទាំដោយការប្រុងប្រយ័ត្ន ជាទីបំផុតទើបឃើញថា បន្ទុកការលំបាករបស់មនុស្សចាស់អាស៊ីបានខ្លះ ។ អ្នកស្រីបានផ្តើមសេវាថែទាំមនុស្សចាស់នៅផ្ទះពីម្នាក់ពីរនាក់ រហូតដល់ពេលនេះ សមាគមអ្នកស្រីបើកបំរើសេវាសុខភាពមនុស្សចាស់និងមនុស្សពិការជំទង់ចំនួន ៣០៣នាក់ ។ ការងារដែលជាវិជ្ជាជីវៈថ្មីមួយ បានកើតឡើង បំពេញសេចក្តីត្រូវការសុខភាពរបស់មនុស្សចាស់នៅក្រុងហ្វីឡាដែលហៀវបានគួរឱ្យគោរព ។ ការរីកចំរើនដ៏ឆាប់រហ័សនេះក៏ដោយសារមានសេចក្តីត្រូវការសេវាដ៏ធំធេង នៃចំនួនមនុស្សចូលដល់វ័យចាស់ ត្រូវការកិច្ចការថែទាំកាន់តែច្រើន ហើយបើទោះបីជាសេវាសាធារណៈ ខិតខំជួយតាមគំរូជំនួយចាស់គឺបានចំណាយច្រើនតែបានផលតិច ហេតុនេះ ហើយបានជាសេវាផ្តើមដោយអ្នកស្រី អ៊ិម ជា ឆយ បានទទួលការគាំទ្រកាន់តែខ្ពស់ ហើយមានប្រជាប្រិយភាពច្រើនឡើងជាលំដាប់ ។

មិនត្រឹមតែប៉ុណ្ណោះ សមាគម Passi បាន ខិតខំលើកទឹកចិត្តសកម្មភាពបំរើសេវាដល់មនុស្សចាស់អាស៊ី ដែលមានការលំបាកនឹងធ្វើឱ្យគេយល់ដោយភាសានិងវប្បធម៌ដើមរបស់ខ្លួនដោយនាំមកបង្ហាញ និងការកោតសរសើរជាសាធារណៈដល់បុគ្គលិកដែលខិតខំបំពេញភារកិច្ចរាល់ថ្ងៃប្រកបដោយភាព ចំណូលចិត្ត និងគុណភាពខ្ពស់ ដូចជា អ្នកជា បៃលី- លីឌីណា កិម -សួជនឡី -សីកៅតាំ ជាដើម។ បន្ថែមពីលើនេះទៅទៀត គណកម្មាធិការនាយក Passi បានសម្លឹងឃើញ អង្គការមួយចំនួនទៀត ដែលផ្តោតការយកចិត្ត ទុកដាក់ទៅលើសេវាថែទាំដល់មនុស្សចាស់ អាស៊ីយ៉ាងយកចិត្តទុកដាក់ប្រកបដោយ គុណភាពខ្ពស់គួរឱ្យកោតសរសើរបានដូចជា: សមាគមខ្មែរនៅហ្វីឡាដែលហៀវ ដំណាងដោយ អ្នកស្រី រ៉ង សិន នាយិកាប្រតិបត្តិ -សមាគម ស៊ីម៉ាក ដំណាងដោយលោក ថយ ង្វៀង នាយកប្រតិបត្តិ -អង្គការប្រព័ន្ធសុខភាពនៅអាប៊ិន តុន ដំណាងដោយលោក ឡារី មើលីស នាយកប្រតិបត្តិជាដើម ក៏បានត្រូវអញ្ជើញឱ្យមកបង្ហាញខ្លួន ហើយទទួលការកោតសរសើរជាសាធារណពីអ្នកស្រី Alma Jacobs និង Rosemary Leyland គណកម្មការនាយក Passi នារាត្រី សមោសរនោះដែរ ។



ថយ ង្វៀង និង រ៉ង សិន ទទួលការកោតសរសើរពី Passi



ឡារី មើលីស ទទួលការកោតសរសើរពីគណកម្មាធិការនាយកPassi

រាត្រីទទួលភ្ញៀវរបស់សមាគមPassiនេះ បានក្លាយទៅជារាត្រីសមោលសរប្រកបដោយទស្សនីភាពដ៏គួររំភើបបាន ដោយអ្នកស្រីពិធីករ ឡូរ៉ែន បាឡាមូរីល ដ៏មានបទពិសោធន៏ខ្ពស់ជានាយកវិទ្យុខ្សៀ និងជាជ័យលាភីក្នុងការផ្សព្វផ្សាយ ចូលរួមដឹកនាំកម្មវិធីធ្វើឱ្យទាក់ទាញអារម្មណ៍ភ្ញៀវរហូតដល់ចប់ ។ ជាមួយគ្នានោះក៏មានការបង្ហាញរបាំបូរាណ ដែលនៅក្រាញពុំព្រមរលត់ បើទោះជាមានការគាបសង្កត់យ៉ាងណាក្តី គឺរបាំជូនពររបស់ខ្មែរដែលមានកំណើតតាំងពីសតវត្សទី៣ រាំដោយឡានីកា និងរបាំចិនបូរាណសម្តែងដោយក្រុមយុវនិស្សិតរបស់ក្រុមហ្វាលុងគុង ដែលកំពុងមានប្រវត្តិជូចត់ជាមួយរដ្ឋអំណាចចិនសព្វថ្ងៃនៅឡើយ ។

រាត្រីដ៏គួរឱ្យចងចាំបានកើតឡើងជាលើកទី ៦ ដោយសាសហគមន៍ទាំងមូល បានបង្ហាញការគាំទ្រដល់ស្មាដែសប្បុរសចំពោះមនុស្ស ចាស់ ដ៏ត្រចះត្រចង់ដែលបានផ្តើមពីភាពធម្មតាមួយនៃការស្រឡាញ់រវាងម្តាយនិងកូនស្រី - ឥឡូវនេះបានក្លាយជាសម្បត្តិដ៏មានប្រយោជន៏របស់សហគមន៏ ដល់វិស័យថែរទាំមនុស្សចាស់ដែលមានបញ្ហាភាសា ។ អ្នកស្រី អ៊ិម ជាឆយ និង Passi កំពុងផ្តល់សំណាងដ៏ធំធេងដល់រដ្ឋផេនស៊ីវេនា និងជាគំរូដល់ស.រ.អាទាំងមូលទៀតផង ៕



ទស្សនារបាំបុរាណចិន

# សកម្មជនការពារព្រៃឈើ ឈុត វុឌ្ឍី បានត្រូវតម្រួតយោធាបាញ់សម្លាប់

លោក ឈុត វុឌ្ឍី គឺជានាយកអង្គការការពារធនធានធម្មជាតិធ្វើការយ៉ាងសកម្មប្រមាណ១៥ឆ្នាំ ជាពិសេសនៅភ្នំក្រវាញដែលបានទទួលស្គាល់ថា ជាតំបន់ត្រូវការការពារ លោកត្រូវបានតម្រួតយោធាបាញ់សម្លាប់កាលពីថ្ងៃទី២៦ ខែ មេសា កន្លងទៅបន្ទាប់ពីលោកនាំអ្នកកាសែតខាំបូឌាដេលីពីរនាក់ទៅយកព័ត៌មាននៅព្រៃការពារ នាខេត្តកោះកុង អ្នកកាសែតពីនាក់នោះ គឺ ភួង បុប្ផា និង អូឡេស្យា ផុតី ។



លោក ឈុត វុឌ្ឍី

ឈុត វិឌ្ឍី បានត្រូវតម្រួតយោធាឃាត់ខ្លួននាវេលាថ្ងៃត្រង់ ហើយទាដកយករូបដែលបានថតក្នុងតំបន់ បន្ទាប់ពីមានការប្តឹងប្តល់ពីក្រុមហ៊ុនដែលទៅថតនៅកន្លែងដែលពួកគេកំពុងកាប់រំលំដើមឈើធំៗ ។ ក្រុម ឈុត វុឌ្ឍី ធ្លាប់បានបណ្តេញក្រុមហ៊ុនកាប់ឈើច្រើនដែលឃុបឃិតជាមួយអាជ្ញាធរខេត្តដើម្បីកាប់ឈើខុសច្បាប់ ដូចជា ក្រុមហ៊ុន MSD impro expert កាប់ឈើនៅពោធិសាត់ កាលពីខែធ្នូឆ្នាំមុន ។ ដើម្បីការពារខ្លួន ឈុត វុឌ្ឍី មានកាំភ្លើងខ្លីមួយជាប់ខ្លួនជានិច្ចតែពុំមែនជាអ្នកបាញ់គេទេ ។

អង្គការលីកាដូដែលតាមដានការស៊ើបអង្កេតបាននិយាយថា ឥតមានឃើញសញ្ញាថា ឈុត វុឌ្ឍី បានបាញ់នោះទេ តែអ្នកនាំពាក្យតម្រួតយោធា ខេង តិតូ និយាយ-ថា រតនាបានបាញ់រះគ្រាប់ទី១ បានត្រូវ វុឌ្ឍី និងត្រូវ រតនា ហើយ រតនា នៅតែ បន្តបាញ់ វុឌ្ឍី រហូតដល់ស្លាប់ ។ ការស៊ើបអង្កេតនៅមិនទាន់បិទនៅឡើយទេ ។

ឈុត វុឌ្ឍី ធ្វើការជាទូទៅតែម្នាក់ឯងប្រឆាំងទង្វើក្រុមហ៊ុនធំៗ ប្រឆាំងនិងអាជ្ញាធរយោធា និងស៊ីវិល ដែលការពារក្រុមហ៊ុនទាំងនោះ ។ ការបាត់បង់សកម្មជនការពារធម្មជាតិរូបនេះ គឺជាការបាត់បង់យោធាដ៏ស្មោះត្រង់ម្នាក់ដែលការពារកម្ពុជាឱ្យនៅរស់រានមានជីវិត ៕ **អេម៉ុល តុន**

**ដកស្រង់ពី ឡូពីទី សូណាល់**

# បោះឆ្នោតប្រធានាធិបតី បារាំង ឆ្នាំ២០១២

លោក ហ្វ្រង់ស្វា ហុឡង់ បានជាប់ជាប្រធានាធិបតីបារាំង នាឱកាសបោះឆ្នោតសកលកាលពីថ្ងៃទី៤ខែឧសភា ឆ្នាំ២០១២ កន្លងទៅនេះជំនួសលោក សាកូស៊ី ដែលបានកាន់តំណែងប្រធានាធិបតីអស់រយៈពេលឆ្នាំមក។

លោក ហ្វ្រង់ស្វា ហុឡង់ មកពីគណបក្សសង្គមនិយម ដែលជាចរន្តរបស់លោក ហ្វ្រង់ស្វា មីតេរ៉ង់ ប្រធានាធិបតីពីរអណត្តិក្នុង១អណត្តិមាន៧ឆ្នាំ ។ លោក ហ្វ្រង់ស្វា ហុឡង់ មិនមាននយោបាយដូចគ្នា នឹងនយោបាយលោក សាកូស៊ី ដែលប្រកាន់ស្តាំនោះទេ ។ គេធ្លាប់បានឃើញការប្រកាន់យកនយោបាយសង្គមនិយមរបស់បារាំង បានធ្វើឱ្យសេដ្ឋកិច្ចចុះយ៉ាងខ្លាំងធ្វើឱ្យនាយកក្រុមហ៊ុនជាច្រើនចុះធ្វើយុទ្ធនាការបាតុកម្មការពារពាណិជ្ជកម្ម នឹងឧស្សាកម្មច្រើនលើកច្រើនសា ដែលជាទូទៅគឺក្រុមកម្មករទេ ដែលជាអ្នកធ្វើបាតុកម្មនោះ ៕



ហ្វ្រង់ស្វា ហុឡង់

ទំព័រកំសាន្ត

គឹម ភៀន

# កុំលែងគ្នាអីអូនអើយ ចាំខ្ញុំស្លាប់តាម ម៉ែវាឯងនឹងកូនម្តង!



បានដែបន្ថែមទៀត "រអ៊ូអី? ចង់លែងគ្នាមែនទែនទេ ដើរចេញពីផ្ទះនេះនៅខ្ញុំឯណោះទេ ដែលជាម្ចាស់ផ្ទះនោះ តែបើប៉ាវាឯងចង់ឱ្យខ្ញុំចេញ ខ្ញុំទៅតែ(ជួលផ្ទះជាមួយគ្នា)បន្ទប់ជាមួយពួកម៉ាក ខ្ញុំនៅអៀងអើយទៅធ្វើការមកវិញ ដេកដល់ពេលណាក៏បានមិនបាច់ខ្វល់ធ្វើម្ហូបបំរើអស់លោកនយោបាយយកមេឃទ្រាប់តួចអង្គុយណឹងទៀត ។ តែខ្លាចវាគ្មានប្រាក់បង់ថ្លៃទឹកភ្លើងនឹងឈ្នួលផ្ទះគេ ព្រោះលុយស្តេចប៉ាវាឯងមិនគ្រប់អន្ទងគ្នាមកផឹកស៊ី បានប៉ុន្មានដងផងវាអស់ខ្ទេចបាត់ទៅហើយ ។ ខ្លាចម្ចាស់ផ្ទះគេមករើអាវខោនឹងរបស់របរគ្រវាត់ចេញក្រៅផ្ទះអស់ទៅ!...កុំខ្លាំងពេកតិចខ្ញុំអត់ទ្រាំលែងបានយើងចែកផ្លូវគ្នាដើរមិនខាន...ផ្លូវអាណាអាណុងទៅ។ ខ្ញុំមកធ្វើខ្ញុំបំរើប៉ាវាឯងជិត៣០ឆ្នាំ ហើយខ្ញុំបានអី? ក្មេងគេមកក្រោយៗសោះគេមានមាឃាទទិញបានផ្ទះសំបែងមានឡាន"ស្មេ រ៉ូម៉ាយ"បើកបញ្ជិះប្រពន្ធកូនគេយ៉ាងហឺហា បែរឯងមានឡានដែរ តែមុនទៅណាមកណាខំជញ្ជូនទឹកបូនដប់ដបយកទៅតាម.បន្តិចចុះចាក់ទឹកបន្ថែម. តិចចុះចាក់បន្ថែមទៀត ព្រោះក្តៅម៉ាស៊ីនពេកឡានឡោកម៉ាស៊ីនអស់គ្នាចេះតែស្រេកទឹក ។ គាប់ជួនពេលមួយនោះឡានបើកទៅមុខលែងរួចក៏ឡាំប៉ាកកណ្តាលភ្លើងស្តុប.រុញទៅមុខមិនរួច.រុញមកក្រោយមិនបាន.ប៉ូលិសចង់ជួប "តិកខេត" មួយសន្លឹកហើយ សួរថា "may i help you sir?" (លោកត្រូវការឱ្យខ្ញុំជួយឬ?)ប៉ាវាឯងតាំងស្មេញ.មុខឡើងស្លាំង.បានខ្ញុំតើ.ជាអ្នកស៊ីលុយស្តេចពីជំងឺពីឆ្កួតឆ្លើយជំនួស "No Sir , thank you,our car is thirsty,it wants to drink water" លោកប៉ូលិសមិនដែលឃើញឡានចំឡែកក៏ស្រែកដោយអស់សំណើច : "Oh wow!"ខ្ញុំចាក់ទឹកមួយដបឱ្យឡានផឹក ហើយខ្ញុំក៏រត់រឹងឡើងឡានបិទទ្វារជិតភ្លាមកុំឱ្យមានអ្នកស្គាល់គេឃើញទាន់វាអាម៉ាស់មុខពេកទៅណា៎! ។ តើប៉ាវាឯងយល់ពីការអាម៉ាស់របស់ខ្ញុំខ្លះៗទេ?" ។ លោកប្តីឧត្តមសេនីយ៍ទ្រង់ស្រពោនបន្តិច:"មកពីយល់នឹងអាណិតម៉ែវាឯង ហើយទើបខ្ញុំចេះតែខំប្រឹងទាក់ទង.អន្ទងក្រុមនេះក្រុមនោះមកជប់លៀងគេស្គាល់យើងឱ្យ ហើយដល់ក្រុមណាគេបានជោគជ័យយើងបានខ្ពស់មុខជាមួយគេអញ្ចឹងទៅដែរ!" ។ លោក"ជំទាវ"ទ្រង់អស់សំណើច: "នយោបាយរបៀបបងគេហៅថា (នយោបាយមុខច្បូក ឬនយោបាយចាក់ខ្សែ)មិនខ្ចីដឹងបន្ទាត់នយោបាយស្អីទេ ដឹងតែពីរឿងឈ្នះ.ចង់ធ្វើយ៉ាងម៉េចយ៉ាងម៉ាអី ក៏ប៉ាវាឯងទៅតាមទាំងអស់ឱ្យតែបានឈ្នះ ។ ក្រុមមិនខុសពីក្រុមមមាចចាំតែនាំគ្នារត់ចូលភ្លើង ព្រោះយល់ថា ជាចំណីនោះទេ ។ សុំទោសប៉ាវាឯងផងចុះមិនមែនចង់បង្អាប់បងអីទេ តែខ្ញុំនៅកន្លែងធ្វើការក៏មានជជែកគ្នាពីរឿងស្រុកទេសយើង.មានអ្នកគេចេះដឹងខ្លះៗគេនិយាយគ្នាខ្ញុំចេះតែស្តាប់នឹងគេទៅពេលសម្រាកញ៉ាំបាយថ្ងៃឬពេលញ៉ាំអាហារស្រាល(ស្នាក់)ខ្ញុំក៏យល់ខ្លះៗដែរ។ គេចង់ឱ្យស្រុកសុខសប្បាយចង់ឱ្យអ្នកនយោបាយ" រួបរួមគ្នាកសាងស្រុកទេសទប់ទល់ជាមួយគ្នាប្រឆាំងនឹងសត្រូវជិតខាងឈ្លានពានម៉េចទៅជាក្រុមប៉ាវាឯងចង់តែឱ្យវាយគ្នាបាក់បែកខ្ទេចខ្ទីអាល់ខ្លួនបានទៅធ្វើធំសប្បាយត្រួត ។ សម័យនេះហើយមាត់និយាយប្រជាធិបតេយ្យតែដៃទាំងពីរក្តាប់ជានិច្ច ។ តែខ្លួនឯងមិនហ៊ានរើទេ ចាំឱ្យគេរើគ្នាឱ្យងាប់អស់សិនចាំខ្លួនទៅលើកទង់ស្រែក: "ឈ្នះហើយៗ"ដណ្តើមយកជ័យភ័ណ្ឌនឹងជ័យផល" ។ គ្មានសំឡេងឆ្លងឆ្លើយទៀត.លោកជំទាវលួចសម្លឹងមុខប្តីដែលកំពុងនៅក្រោមសំពាធនៃក្តីទុក្ខអស់សង្ឃឹម ហើយដកដង្ហើមវែង។

ឃើញប្តីបន្ថយបន្ទូរស្រគី"ឧត្តមសេនីយ៍"ចេញបានខ្លះហើយ លោក"ជំទាវ"ទ្រង់អាណិតប្តីខ្លះដែរ ទើបបន្ទូរចំហាយនៃក្តីក្តៅក្រហាយចេញខ្លះបាន ក៏មានសំដីទន់មកវិញបន្តិច : "មានពេលខ្លះនឹកអាណិតប៉ាវាឯងដែរ ធ្លាប់មានបុណ្យសក្តិលើគេឯងបន្តិចបន្តួច មកដល់ណោះចង់តែត្រួតគេទៀតម្តេចកើត តម្រេះវិជ្ជាគ្មានហើយមិនចេះបន្ទន់ខ្លួនបត់មែនតាមកាលៈទេសៈ នឹងស្ថានភាពជាក់ស្តែង នៅតែចង់ក្រអើតក្រទម ។ ខ្ញុំក៏ចេះតែបណ្តោយទ្រាំនឿយទ្រាំហត់ខ្មាស់អៀនតែម្នាក់ឯងទៅ ទុកឱ្យប៉ាវាឯងបានសប្បាយចិត្ត កុំតែធ្វើអីផ្តេសផ្តាសមានទោសដល់ខ្លួន.លំបាកដល់គ្រួសារ ។ តែប៉ាវាឯងហាក់ដូចមិនយល់ពីការទុក្ខលំបាករបស់កូនប្រពន្ធសោះគិតកាន់តែខុសធ្ងន់ទៅៗសង្ឃឹមតែលើផ្កាយលើលោកខែដេកតែបន់ឱ្យវាទៅជាយ៉ាងនេះយ៉ាងនោះ ដើម្បីឱ្យបានធ្វើធំបានត្រួតគេហឺហា... យ៉ាងណឹងយ៉ាងណឹងវាគ្មានទេ ! ប៉ាវាឯងចាំតែ មើលទៅ! ហ៊ុនសែនដួលរលំឬ? យើងឯណោះទេ. អ្នកនយោបាយយកមេឃទ្រាប់អង្គុយដែលដួលមុន ហ៊ុន សែន ថ្ងៃនេះឬស្អែកក៏មិនដឹង ព្រោះគិតតែស៊ីៗផឹកៗគ្មានគិតធ្វើការរកស៊ីអីរំពឹងតែលើប្រាក់ខែស្តេចបន្តិចបន្តួចសេដ្ឋកិច្ចស្រុកនេះកំពុងតែចុះទ្រុឌទ្រោម ។ ថ្ងៃណាមួយទ្រាំមិនបានរដ្ឋគេកាត់អស់ប្រាក់ខែស្តេច ឬក៏កាត់ពាក់កណ្តាលសិនលោកអ្នកនយោបាយត្បាញអាយទាំងនេះគាត់ទៅច្បាំងជាមួយអ្នកណាទៀត ដើម្បីឡើងកាន់អំណាចហើយបានធ្វើធំ? ហ៊ុនសែនមិនងាយរលំទេ ព្រោះជំនួយហូរចូលមិនងាយចប់គាត់ដៀលទាំងអង្គការសហប្រជាជាតិ.ក្រអើតក្រទមដាក់ទាំងអាមេរិកាំង.ជំនួយនៅតែហូរចូល ព្រោះគេខ្លាចរាស្ត្រខ្មែរអត់បាយ ។ ប៉ាវាឯងហ៊ានតែក្រអើតក្រទមដាក់ខ្ញុំរបៀបណឹងម៉េវ៍បើមិនចែកផ្លូវគ្នាខ្ញុំសុំភ្នាល់!" ។

ខំធ្វើស្ងួតប៉ុណ្ណឹងហើយនៅតែប្រពន្ធខំឡើងចាងទៀត លោកឧត្តមសេនីយ៍ បែរមកបង្ហាញពីហេតុផលដែលនាំឱ្យគាត់សង្ឃឹមនោះម្តងវិញ : "ម៉ាក់វាឯងមិនទាន់ដឹងទេណឹងអី? មើលប្រទេសអារ៉ាប់ទាំងឡាយដូចអ៊ីរ៉ាក់.អេហ្ស៊ីប.លីប៊ី...លោកខាងលិចនឹងអាមេរិកាំង ទៅវាយកំទេសអាពួកមេផ្តាច់ការទម្លាក់ចោលអស់.លើកមេដឹកនាំខាងប្រជាធិបតេយ្យឱ្យឡើយកាន់ជំនួស. ដឹកនាំប្រទេសវិញ ។ ឥឡូវប្រទេសស៊ីរីជិតដល់ពេលទៀតហើយ ។ ចប់ពីនេះទៅ ហ៊ុន សែន នឹងដល់វេនម្តង មិនយូរទេ ម៉ែវា ចាំតែមើលទៅ! គេបំពាក់សក្តិឱ្យពួកបង គឺមកពីហេតុការណ៍ណឹងឯង!" ។

ដោយដឹងថា ប្តីជាប់ញៀននឹងក្តីសង្ឃឹមឆ្កួតលីលាយ៉ាងណឹង"លោកជំទាវ"ក៏ដកដង្ហើមវែងហើយធំ"មាន់មិនទាន់រងាវទេ ប៉ាវាឯងអើយ! ដុតចង្កៀងឈ្ងូលមើលផ្លូវសិនទៅ កុំអាល់ចេញដើរទាំងងងឹតងងល់គ្រោះថ្នាក់ខ្លាំងណាស់កុំ

តទៅទំព័រទី១៨


# ពេទ្យធ្មេញសំរាប់គ្រួសារ Caring Dental For ALL Ages




COMPLETE ផ្តល់គ្រប់សេវាកម្ម Services

- Cosmetic Dentistry
- Cosmetic Fillings
- Crowns & Bridges
- Dentures
- Extractions
- Implant Crowns
- Root Canal Therapy

- ត្រួតពិនិត្យទៀតទាត់ពេល
- សំអាតធ្មេញ
- ជំងឺចញ្ចាញធ្មេញ
- ដកសរសៃធ្មេញ
- ស្រោប-តម្រឹម និងប៉ះធ្មេញ
- ធ្វើធ្មេញឱ្យស
- បំពេញធ្មេញប្រហោង
- ដកធ្មេញ

Most Forms of Insurance & Payment
ACCEPTED ទទួលគ្រប់ អ៊ិនស៊ូរិន
MassHealth • Cigna • Aetna
Amex • Discover • Visa • Mastercard

Convenient LOCATION
Next to Bank of America on Chelmsford Street



FREE Teeth Whitening
New patients get a complimentary teeth whitening kit with completed exam, cleaning & x-rays at regular price. Cannot be combined with any other offers. Expires 30/04/2012

"EXCLUSIVE OFFER" $55.00
Limited Time New Patient Special
(Regular Discount $55.99 a $250 Value)
Present coupon for discount. Includes exam, bite-wing x-ray & cleaning. Cannot be combined with other offers or insurance. Expires 30/04/2012

យើងមានអ្នកនិយាយភាសាខ្មែរ អង់គ្លេស ស្បានីស និងវៀតណាម សូមទូរស័ព្ទ 978-455-4039 ដើម្បីណាត់ជួបនាថ្ងៃនេះ

724 Chelmsford Street • Lowell, MA • 978-455-4039
www.BrightSmiles-Dental.com

តមកទំព័រទី ១

# សហគមន៍ខ្មែរនៅតំបន់ញូអិនគ្លិន...





ខែឧសភា ឆ្នាំ២០១២នេះឡើង ។ គំនិតប្រេសក្លឹបនេះ គឺឧទ្ទិសដល់ទិវាអន្តរជាតិនៃសេរីភាពសារព័ត៌មាន ដែល អ.ស.ប ប្រារព្ធនៅថ្ងៃទី៣ ខែឧសភា នារៀងរាល់ឆ្នាំ សម្រាប់រំលឹកប្រជាជាតិពីការប្រើសេរីភាពក្នុងការនិយាយស្ដី ការផ្សព្វផ្សាយនូវគំនិតនឹងព័ត៌មានជាសាធារណ ចែករំលែកចំណេះដឹងទៅវិញទៅមក ដែលការផ្សព្វផ្សាយនេះ ជាឧបករណ៍នៃការអភិវឌ្ឍន៍សង្គមនឹងមនុស្សយ៉ាងជាក់ស្ដែង ។ គំនិតទីពីរ គឺឧទ្ទិសដល់គ្រួសារខ្មែរពីរគ្រួ ដែលខិតខំកសាងកិត្តិយសជាពលរដ្ឋអាមេរិកាំង ដើមកំណើតខ្មែរ ហើយបានជាប់ឆ្នោតជាមន្ត្រីក្រុងដ៏សំខាន់បំផុត ជាគំរូនៃជោគជ័យដំបូងចាប់តាំងពីខ្មែរយើងបានមកដល់ដែនដីអាមេរិក តាំងពីជាង៣០ឆ្នាំមកហើយ ។ ក្នុងគំនិតធំជាងនេះ យើងបានបង្កើតបរិយាកាសពិសេសមួយ សម្រាប់នាំដំណើរសហគមន៍ឱ្យប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ មកបំពងសំឡេងឱ្យបានឮប្រកបដោយភាពទទួលខុសត្រូវ ដូចជាតិសាសន៍ជឿនលឿនដទៃឯទៀត ។

ភ្ញៀវបានមកជួបជុំគ្នាវេលាម៉ោង៧:៣០នាទីយប់ ធ្វើឱ្យបរិយាកាសក្លាយជាអ៊ូរអរ ផ្ដើមកំដរដោយក្រុមតន្ត្រីបូរាណខ្មែរយ៉ាងរងំ ដឹកនាំដោយលោក សុវណ្ណតារា នាង ភាពអ៊ូរអរក៏ក្លាយទៅជាពិធីបុណ្យនៃមន្ត្រីនិងអ្នកមុខអ្នកការក្នុងតំបន់ញូអិនគ្លិន

-ហើយពិធីបុណ្យនេះ ដឹកនាំដោយពិធីការិនី សុបិន ពិន ជានាយិការគ្រប់គ្រងខ្មែរប៉ុស្តិ៍ និងជាអ្នកជំនាញបទពិសោធន៍ជាពិធីករវិទ្យុខ្មែរនៃអាមេរិកាំង នៅផែនស៊ីវែនាបីឆ្នាំ បានញ៉ាំងឱ្យអ្នកចូលរួមពិធីបុណ្យនេះ អាចផ្ដោចអារម្មណ៍យ៉ាងជ្រាលជ្រៅទៅលើគុណប្រយោជន៍នៃការផ្សព្វផ្សាយគំនិត និងដំណឹងរបស់វាគ្មិន ហើយអាចចង់ចាំបានយូរ នៅព្រឹត្តិការណ៍កើតឡើងសម្រាប់ជាកិត្តិយសជូនភ្ញៀវម្នាក់ៗបាន ។ ដើម្បីការចងចាំនេះទៀត ក្រុមអ្នកឯកទេសខាងថតរូបនិងសំឡេង ដឹកនាំដោយស្ទូឌីយោ"មិតប៊ូក្រេត" របស់លោក វាស្នា គង់ ក៏បានចម្លងទុកព្រឹត្តិការណ៍ដ៏សំខាន់នេះ ជាអមតៈរួចហើយដែរ ។

